ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំឆ្នាំ២០២១

ក្នុងឆ្នាំ២០២១នេះ ថ្នាក់ដឹកនាំ សមាជិក សមាជិកា និងគណៈកម្មការនានារបស់ព្រឹទ្ធសភា បានខិតខំបំពេញការងារ ដើម្បីអនុវត្តតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនយ៉ាងសកម្ម តាមបែបគន្លងប្រក្រតីភាពថ្មី ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយទទួលបានលទ្ធផលដូចខាងក្រោម៖

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន ៖**

-បំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន៣លើក។

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន៧លើក ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន៣លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំនានាចំនួន៥លើក។

**ខ-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ**

-អនុញ្ញាតឱ្យថ្នាក់ដឹកនាំប្រទេសជាមិត្ត គណៈប្រតិភូជាន់ខ្ពស់ជាតិ អន្តរជាតិ និងអង្គទូតនានា ចូលជួបជូនសារតាំង សម្តែងការគួរសម សវនាការ និងជម្រាបលា ចំនួន១២លើក។

**គ-សកម្មភាពចុះមូលដ្ឋាន**

-នៅក្នុងសភាពការណ៍នៃការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដោយព្រឹត្តការណ៍សហគមន៍ ២០ កុម្ភៈ សម្តេចប្រធានបានអញ្ជើញមកប្រចាំការរៀងរាល់ថ្ងៃ ដើម្បីដឹកនាំការងារជំនាញ និងដឹកនាំចាត់ចែងចូលរួមចំណែកដោះស្រាយជំនួយឧបត្ថម្ភបន្ទាន់ រួមមាន៖ អង្ករ ត្រីខកំប៉ុង ទឹកត្រី ទឹកស៊ីអ៊ីវ ទឹកផ្លែ

ឈើ ឱសថ និងសម្ភារប្រើប្រាស់មួយចំនួនជូនមន្ត្រី កងកម្លាំង និងប្រជាពលរដ្ឋក្រីក្រ ដែលរងផលប៉ះពាល់ពីការបិទខ្ទប់នៅក្នុងមូលដ្ឋានរាជធានីភ្នំពេញជាបន្តបន្ទាប់។ ព្រមជាមួយនេះ សម្តេចប្រធានក៏បានណែនាំ ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកាព្រឹទ្ធសភា ជាទីប្រឹក្សាថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភា ឱ្យជួយដោះស្រាយនូវអំណោយចាំបាច់នានាទៅតាមលទ្ធភាព ដើម្បីចែកជូនប្រជាពលរដ្ឋងាយរងគ្រោះ និងប្រជាពលរដ្ឋក្រីក្រដែលកំពុងរស់នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងខេត្តមួយចំនួនទៀតផងដែរ

-បានចាត់តំណាងនាំយកនូវគ្រឿងឧបភោគ បរិភោគ និងសម្ភារប្រើប្រាស់មួយចំនួនចុះសួរសុខទុក្ខ ចែកជូនប្រជាពលរដ្ឋមានជីវភាពខ្វះខាត និងកំពុងធ្វើចត្តា-ឡីស័កចំនួន៥៧៩គ្រួសារ ប្រជាពលរដ្ឋក្រីក្រជួបការលំបាកក្នុងតំបន់ក្រហមចំនួន១០០០គ្រួសារ មន្ត្រីរាជការ កងកម្លាំងការពារសន្តិសុខសណ្តាប់ធ្នាប់នៃអគ្គលេ-ខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៩៩នាក់ និងសមាគមចលនាវប្បធម៌ជាតិ ដើម្បីកុមារកំព្រា កុមារក្រីក្រ នៅរាជធានីភ្នំពេញ

ក្នុងឱកាសពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ សម្តេចវិបុល-សេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ បានចាត់តំណាង៖

-នាំយកបច្ច័យ ទេយ្យទាន គ្រឿងឧបភោគ បរិភោគ រួមមាន ៖ អង្ករ២តោន ទឹកក្រូច៣០កេះ ទឹកសុទ្ធ៥០កេះ ត្រី៥កេះ មីយើង៥កេះធំ តែ១០គីឡូក្រាម នំខ្មែរ ១៧កន្ត្រក សាដក២១៤កញ្ចប់ ផ្លែឈើ៨កន្ត្រកធំ ក្រណាត់ស៩៥ដុំ ដោយចំណាយបច្ច័យសរុបអស់២៥.៣០០.០០០រៀល និងប្រាក់ដុល្លារ១០.៦០០$ និងថវិកាចំនួន ៩.៣៥០$ សហរដ្ឋអាមេរិកសម្រាប់កសាងវត្ត ព្រមទាំងគ្រឿងឧបភោគ បរិភោគ ផ្សេងទៀតទៅវេរប្រគេនព្រះសង្ឃក្នុងពិធីកាន់បិណ្ឌ នៅវត្តនាគវ័ន វត្តវាលស្បូវ វត្តអង្គបឹងចក និងវត្តបទុមវតី រាជធានីភ្នំពេញ

-នាំយកទេយ្យទាន គ្រឿងឧបភោគ បរិភោគ ភេសជ្ជៈ ផ្លែឈើជាច្រើនមុខ ដើម្បីចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី១២ នៅវត្តវិសុទ្ធវង្សាកណ្តាលកោះសូទិន និងវត្តត្នោត។ ក្នុងឱកាសនោះដែរ សម្តេចក៏បានផ្តល់នូវអង្ករចំនួន២តោន និងថវិកា ចែកជូនប្រជាពលរដ្ឋក្រីក្រសរុបទឹកប្រាក់ចំនួន២៣.០០០.០០០រៀល និងចូលរួមប្រារព្ធពិធីសូត្រមន្តឆ្លងសាលាបុណ្យមួយខ្នង ជាអំណោយផ្ទាល់របស់សម្តេច

និងលោកជំទាវ ជូនប្រជាពលរដ្ឋ នៅឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម

-អញ្ជើញចុះមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន១៦លើក។

**ឃ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-អញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗចំនួន៣០លើក។

**ង-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានចុះហត្ថលេខាលើព្រះរាជក្រមចំនួន២ច្បាប់

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន ១៨៩ច្បាប់

-បានទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន១២២ច្បាប់

-បានទទួលសំណើពីរាជរដ្ឋាភិបាលចំនួន១២២ច្បាប់

-បានទទួលសំណើពីរដ្ឋសភាចំនួន១១២ច្បាប់

-បានទទួលសំណើពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំនួន១ច្បាប់

-បានទទួលសំណើពីឧត្តមក្រុមប្រឹក្សាអង្គចៅក្រមចំនួន១ច្បាប់

-បានផ្តល់យោបល់ និងចុះហត្ថលេខាលើលិខិតផ្សេងៗចំនួន២៩១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៧៨ច្បាប់។

**១.២-ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ីម កា អនុប្រធានទី១ ព្រឹទ្ធសភា បាន ៖**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន២លើក។

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន១០លើក ប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន៤លើក

-អញ្ជើញចូលរួមកិច្ចប្រជុំសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា។

**ខ-សកម្មភាពចុះមូលដ្ឋាន**

-អញ្ជើញចុះមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន៨លើក។

**គ-សកម្មភាពចូលរួមក្នុងពិធីផ្សេងៗ**

-អញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលស្ដីពី ការអភិវឌ្ឍ និងផ្ដល់សេវានៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងធានាបានសុខសុវត្ថិភាព ជូនប្រជាពលរដ្ឋដើម្បីប្រមូលព័ត៌មានទាក់ទងនឹងបញ្ហាប្រឈម និងសំណូមពរនានា ព្រមទាំងឧបត្ថម្ភថវិកាជូនក្រុមប្រឹក្សាសង្កាត់ចំនួន១០៥នាក់ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗចំនួន៥លើក។

**ឃ-ការពិនិត្យ និងផ្ដល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន៦៨ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១៨៦ច្បាប់។

**១.៣-ឯកឧត្ដមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន ៖**

-ទទួលភារកិច្ចជាប្រធានស្ដីទីព្រឹទ្ធសភាចំនួន១លើក។

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន១លើក និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន៩លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន១លើក និងចូលរួមប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន៤លើក

-អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំនានា ដោយផ្ទាល់ និងតាមប្រព័ន្ធវីដេអូ ចំនួន៥លើក

-អនុញ្ញាតឱ្យភ្ញៀវជាតិចូលជួបដើម្បីរាយការណ៍ និងសុំមតិណែនាំការងារចាំបាច់មួយចំនួន ចំនួន៣លើក។

**ខ-សកម្មភាពចុះមូលដ្ឋាន**

-អញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយទៅចែកជូនអាជ្ញាធរ កងកម្លាំង ប្រជាពលរដ្ឋ នៅក្នុងខេត្តកណ្ដាល ចំនួន២៣លើក

-បានចាត់តំណាងនាំយកនូវសម្ភារការិយាល័យ គ្រឿងឧបភោគ បរិភោគ សម្ភារប្រើប្រាស់ និងរទេះជនពិការ ចែកជូនចាស់ជរា ប្រជាពលរដ្ឋកំពុងមានជីវភាពខ្វះខាត និងក្រុមប្រឹក្សាឃុំ នៅខេត្តកោះកុង ខេត្តពោធិ៍សាត់ ខេត្តតាកែវ និងខេត្តកណ្ដាល។

**គ-សកម្មភាពចូលរួមក្នុងពិធីផ្សេងៗ**

-អញ្ជើញជាអធិបតី និងចូលរួមក្នុងពិធីផ្សេងៗចំនួន១៣លើក។

**ឃ-ការពិនិត្យ និងផ្ដល់យោបល់លើឯកសារផ្សេងៗ**

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៣០ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន៤៨៩ច្បាប់។

**២-សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍**

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានបើកសម័យប្រជុំចំនួន១១លើក ដែលមានរបៀបវារៈដូចខាងក្រោម៖

១-ពិនិត្យលើសំណើរបស់រដ្ឋសភាសុំដាក់សេចក្តីព្រាងច្បាប់ចំនួន១៨ច្បាប់។

២-ពិនិត្យ និងសម្រេចលើរបាយការណ៍ទូទាត់ថវិការបស់ព្រឹទ្ធសភាប្រចាំឆ្នាំ២០២០

៣-ពិនិត្យ និងសម្រេចអំពីគោលការណ៍បែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភា ឆ្នាំ២០២១

៤-ការប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី នីតិកាលទី៤

៥-ការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ ព្រឹទ្ធសភា នីតិកាលទី៤។

**៣.សម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ**

ព្រឹទ្ធសភាបានបើកសម័យពេញអង្គ និងប្រជុំជាវិសាមញ្ញចំនួន៥លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន១៨ច្បាប់។

**៤-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា**

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

-បានប្រជុំផ្ទៃក្នុងគណៈកម្មការចំនួន៥០លើក

-បានចុះបេសកកម្មក្នុងប្រទេសចំនួន១០លើក

-បានចូលរួមសិក្ខាសាលា វេទិកា និងកិច្ចប្រជុំនានាចំនួន៥៧៩លើក

-បានទំនាក់ទំនងជាមួយស្ថាប័នជាតិ និងអន្តរជាតិចំនួន៣៦លើក

-បានចូលរួមពិធីផ្លូវការផ្សេងៗចំនួន៣៤០លើក

-សមាជិកគណៈកម្មការនានាបានចុះមូលដ្ឋានដោយឡែករៀងៗខ្លួនចំនួន

១.២៨០លើក។

**៤.១-មុខងារនីតិកម្ម**

-គណៈកម្មការជំនាញព្រឹទ្ធសភាបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន១៨ច្បាប់

-បានអញ្ជើញដឹកនាំប្រជុំត្រួតពិនិត្យ និងពិភាក្សាលើគម្រោងបែងចែក និងការប្រើប្រាស់ថវិកាឆ្នាំ២០២២ របស់ព្រឹទ្ធសភា

-បានអញ្ជើញចូលរួមប្រជុំ ដើម្បីឈ្វេងយល់អំពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូផ្សាយចេញពីរដ្ឋសភា។

**៤.២-មុខងារតាមដានការអនុវត្តច្បាប់**

-បានអញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងសហការី, ឯកឧត្តម **ទិត ចន្ថា** រដ្ឋលេខាធិការប្រចាំការក្រសួងទេសចរណ៍, ឯកឧត្តម **គៀត ច័ន្ទថារិទ្ធ** អគ្គនាយកអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ, មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជួបពិភាក្សាការងារជាមួយមន្ត្រីរដ្ឋបាលខេត្តក្រចេះ ដើម្បីដើម្បីឈ្វេងយល់អំពីការវិវឌ្ឍ បញ្ហាប្រឈម និងចក្ខុវិស័យទៅមុខរបស់ក្រសួង និងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ

-បានអញ្ជើញចុះបេសកកម្មជាមួយប្រតិភូក្រសួងបរិស្ថាន ដឹកនាំដោយឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដើម្បីពិភាក្សាលើករណីប្រជាពលរដ្ឋកាន់កាប់និងអាស្រ័យផល នៅក្នុងដែនជំរកសត្វព្រៃភ្នំត្នោត និងភ្នំពក នៅឃុំស្ពៅ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ

-បានអញ្ជើញចុះបេសកកម្ម ដើម្បីឈ្វេងយល់អំពីប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលើកិច្ចប្រតិបត្តិការរបស់អភិបាល នៃគណៈអភិបាលខេត្ត កងកម្លាំងប្រដាប់អាវុធទាំង៣ប្រភេទរបស់ខេត្ត មន្ទីរទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច និងមន្ទីរមុខងារសាធារណៈ ព្រមទាំងបញ្ហាប្រឈមនានានៅខេត្តកោះកុង

-បានអញ្ជើញចុះបេសកកម្ម ដើម្បីប្រមូលព័ត៌មាន ផ្សព្វផ្សាយ និងតាមដានការអនុវត្តច្បាប់ គោលនយោបាយ ពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ ដោយផ្តោតលើបញ្ហាលើកកម្ពស់សមភាពយេនឌ័រ និងសុខភាពសាធារណៈ ជីវភាពរស់នៅ និងការអនុវត្តការងារតាមបែបប្រក្រតីភាពថ្មី ស្របតាមបរិបទកូវីដ-១៩ នៅខេត្តរតនគិរី និងខេត្តតាកែវ

-បានអញ្ជើញចុះបេសកកម្ម ដើម្បីតាមដាន និងជំរុញការដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ និងឈ្វេងយល់អំពីសិទ្ធិទទួលបានសុខភាព ជាពិសេសស្ត្រី និងកុមារ ក្នុងកំឡុងពេលមានវិបត្តិកូវីដ-១៩ នៅខេត្តបន្ទាយមានជ័យ

-បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំក្រុមអ្នកច្បាប់រាជធានីភ្នំពេញ និងក្រុមអ្នកច្បាប់មកពីខណ្ឌទាំង១៤ កិច្ចប្រជុំក្រុមប្រឹក្សាជាតិ និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិនៃសម្ព័ន្ធភាពជាតិ ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ក្នុងគោលបំណងដើម្បីពិនិត្យអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានា ព្រមទាំងពិនិត្យ និងអនុម័តលើផែនការសកម្មភាពការងារ និងថវិកាសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់

-បានអញ្ជើញជួបពិភាក្សាការងារជាមួយក្រសួងយុត្តិធម៌ គណៈកម្មការសិទ្ធិមនុស្សកម្ពុជា និងគណៈកម្មការទី១ រដ្ឋសភា ដើម្បីឈ្វេងយល់ និងផ្លាស់ប្តូរបទពិសោធន៍ការងារគ្នាទៅវិញទៅមក នៅសាលប្រជុំពិសេសទី៣ ព្រឹទ្ធសភា។

**៤.៣-មុខងារតំណាង**

-បានអញ្ជើញចូលរួមពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការរវាងគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេតនៃព្រឹទ្ធសភា ជាមួយក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន ក្រោមអធិបតីភាពឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា

-បានរៀបចំវេទិកាថ្នាក់ស្រុកចំនួន២លើក នៅស្រុកកងមាស និងស្រុកកោះសូទិន ខេត្តកំពង់ចាម ស្តីពីការលើកកម្ពស់ការផ្តល់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព តម្លាភាព និងការអភិវឌ្ឍមូលដ្ឋាន និងបានរៀបចំពិធីសំណេះសំណាលចំនួន១លើក នៅស្រុកវើនសៃ ខេត្តរតនគិរី ជាមួយប្រធានក្រុមប្រឹក្សាឃុំ នាយប៉ុស្តិ៍នគរបាល

រដ្ឋបាលឃុំ ស្មៀនឃុំ សមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ និង អាជ្ញាធរស្រុក មានអ្នកចូលរួមសរុបចំនួន១៩៦នាក់

-បានពាក្យបណ្ដឹងសរុបចំនួន៥០ករណី ធ្វើលិខិតអន្តរាគមន៍បញ្ជូនពាក្យបណ្ដឹង ទៅអាជ្ញាធរខេត្ត និងក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធពិនិត្យដោះស្រាយចំនួន ៤៣ករណី បញ្ជូនពាក្យបណ្ដឹងទៅក្រុមមេធាវីស្ម័គ្រចិត្តសម្ដេចតេជោសែនចំនួន២ ករណី តម្កល់ទុកមិនចាត់ការចំនួន២ករណី ដោះស្រាយបញ្ចប់ចំនួន១ករណី ទទួល លិខិតឆ្លើយតបពីលទ្ធផលនៃការដោះស្រាយពាក្យបណ្ដឹងរបស់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធចំនួន១៣ករណី និងបានឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន៤៣ករណី និង បានទទួលឯកសារពាក្យបណ្ដឹងដែលក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការ ដើម្បីជូនជ្រាបចំនួន២៩ករណី

-បានអញ្ជើញចូលរួមដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធបុព្វការីជន ក្នុងឱកាស បុណ្យខួបអនុស្សាវរីយ៍លើកទី៦៨ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងថ្វាយកម្រង ផ្កាគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ "ព្រះបរម រតនកោដ្ឋ"** ដឹកនាំដោយឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា នៅវិមានឯករាជ្យ និងនៅមណ្ឌបសួនច្បារខាងកើតវិមានឯករាជ្យ

-បានអញ្ជើញគោរពវិញ្ញាណក្ខន្ធ និងចូលរួមពិធីបូជា និងបញ្ចុះសពលោកជំទាវ **ឱ សុខុម** សមាជិកគណៈកម្មការទី២ និងជាសមាជិកាក្រុមសមាជិកព្រឹទ្ធសភាប្រចាំ ភូមិភាគទី៨ និងឯកឧត្តម **សុខ ឃាត** សមាជិកគណៈកម្មការទី៧ នៃព្រឹទ្ធសភា និង ជាសមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះ សំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់ លំដាប់ថ្នាក់ ព្រមទាំងនាំយកអំណោយ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋ ដែលមានជីវភាពខ្វះខាត និងបានបំពេញភារកិច្ចផ្សេងៗទៀតនៅមូលដ្ឋានរាជធានី ភ្នំពេញ និងតាមបណ្ដាខេត្ត ក្រុងនានាចំនួន១.២៤០លើក។

### ៥.៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ

-សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិនានា ដោយផ្ទាល់ និងតាមប្រព័ន្ធវីដេអូចំនួន៣១លើក រួមមាន ៖ កិច្ចប្រជុំគណៈកម្មការនាយកប្រើភាសាបារាំង និងប្រជុំបណ្តាញស្ត្រីសភានិយាយភាសាបារាំង, កិច្ចប្រជុំគណៈកម្មការនយោបាយ, កិច្ចប្រជុំគណៈកម្មការកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍នៃក្រុមសភានិយាយភាសាបារាំង, កិច្ចប្រជុំគណៈកម្មការកិច្ចការសភា, កិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង, កិច្ចប្រជុំក្រុមសភាជាតិកម្ពុជា និងគណៈកម្មការអប់រំ ទំនាក់ទំនង និងវប្បធម៌នៃសភា ប្រើភាសាបារាំង(APF), កិច្ចប្រជុំរវាងសភាសមាជិកអាយប៉ា និងសភានៃព្រះរាជាណាចក្រណ័រវេស៍, កិច្ចប្រជុំសភាប្រចាំឆ្នាំរបស់សហភាពអន្តរសភា(IPU) ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីស្តារឡើងវិញនូវទំនុកចិត្តលើរដ្ឋាភិបាល និងធ្វើឱ្យប្រសើរឡើងវិញនូវទស្សនវិស័យនៃការអភិវឌ្ឍ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសហភាពអន្តរសភា(IPU) និងអង្គការសហប្រជាជាតិ, កិច្ចប្រជុំសមាគមអគ្គលេខាធិការសភា(ASGP), កិច្ចប្រជុំស្តីពីការជំរុញភាពជាដៃគូសភា ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងឆ្លើយតបចំពោះវិបត្តិកូវីដ-១៩ ក្នុងតំបន់ត្រីកោណអភិវឌ្ឍកម្ពុជា-ឡាវ-វៀតណាម, កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការសង្គម និងវប្បធម៌ នៃសភាតំបន់អាស៊ី(APA), កិច្ចប្រជុំគណៈកម្មការ កិច្ចការបរទេសនៃសភាកម្ពុជា-ឡាវ-វៀតណាម(CLV), កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប Asian-Europe Parliamentary Partnership លើកទី១១ (ASEP-11), កិច្ចប្រជុំសភាពិភពលោកលើកទី១ ស្តីពីការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្រោមមូលបទ " ការប្រែក្លាយបញ្ហាប្រឈម នៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ទៅជាឱកាសសម្រាប់សភាក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព", កិច្ចប្រជុំចំពោះកិច្ច(AD-hoc) នៃវេទិកាសមាជិកសភាអាស៊ី-ប៉ាស៊ីហ្វិកទទួលបន្ទុកសុខភាពពិភពលោក (APPFWGH) ក្រោមប្រធានបទ " ជំងឺកូវីដ-១៩ និងការយកចិត្តទុកដាក់អំពីសុខមាលភាពបឋមនាពេលអនាគត ", កិច្ចប្រជុំប្រចាំឆ្នាំលើកទី២៩ នៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក (APPF-29), មហាសន្និបាត

សហភាពអន្តរសភា(IPU) លើកទី១៤២ និងលើកទី១៤៣, មហាសន្និបាតប្រចាំឆ្នាំនៃបណ្តាញក្រុមសីលធម៌របស់សមាជិកសភានិយាយភាសាបារាំង, មហាសន្និបាតអន្តរសភាអាស៊ាន(AIPA) លើកទី៤២, វេទិកាសភាអាស៊ី-អឺរ៉ុប ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ និងសិក្ខាសាលាស្តីពី ស្ត្រី និងសេដ្ឋកិច្ចគ្រួសារជាស្នូល

-សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញជួបសវនាការ ពិភាក្សាការងារ និងសម្តែងការគួរសមជាមួយភ្ញៀវជាតិ និងអន្តរជាតិចំនួន៣៨លើក។

ថ្ងៃចន្ទ ១កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែមករា ឆ្នាំ២០២២

ជ.ប្រធានព្រឹទ្ធសភា

អនុប្រធានទី២

កិត្តិសង្គហបណ្ឌិត ទេព ងន

*ចម្លងជូន:*

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ខូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*